# សេចក្តីប្រកាសព័ត៌មាន

## ក្រសួងកិច្ចការនារីជម្រុញការឆ្លើយតបជាថ្មីរបស់រដ្ឋាភិបាលដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី

**ភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី ៤ ខែកក្កដា ឆ្នាំ ២០១៦** – ថ្ងៃនេះ ក្រសួងកិច្ចការនារី បានដឹកនាំនូវកិច្ចប្រជុំពិសេសមួយ ដោយមានតំណាងមកពី ១៥ក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដើម្បីជម្រុញការអនុវត្ត និងការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពជាតិ ទី២ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដែលជាគោលនយោបាយជាតិដ៏សំខាន់មួយដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហាអំពើហិង្សាប្រព្រឹត្តដោយដៃគូជិតស្និទ្ធ និងអំពើហិង្សាផ្លូវភេទនៅក្នុងប្រទេសកម្ពុជា។ ក្នុងកិច្ចប្រជុំនេះ ប្រព័ន្ធរាយការណ៍ថ្មីមួយត្រូវបានបង្កើតឡើងនៅក្នុងរដ្ឋាភិបាលដើម្បីបង្កើននូវគណនេយ្យភាព របស់ក្រសួងពាក់ព័ន្ធ និងដើម្បីកំណត់សម្គាល់ និងឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី។

នៅក្នុងសុន្ទរកថា លោកជំទាវ វេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី បានមានប្រសាសន៍ថា៖ "ខណៈពេលយើងកំពុងនិយាយនៅទីនេះ មានស្ត្រីកំពុងទទួលរងនូវអំពើរំលោភបំពាន និងអំពើហិង្សា ឬត្រូវបានសម្លាប់ដោយសហព័ទ្ធ និងដៃគូរបស់ពួកគេនៅទូទាំងប្រទេសកម្ពុជា។ ខ្ញុំសង្ឃឹមថា វិធីសាស្ត្រធ្វើការងារថ្មី និងយន្តការរាយការណ៍ដ៏សាមញ្ញជាងមុនដែលយើងបានអនុម័តក្នុងថ្ងៃនេះ នឹងជួយក្រសួងពាក់ព័ន្ធទាំងអស់ឲ្យធ្វើការប្រឹងប្រែងជាថ្មី និងធ្វើការតៀងគរ នូវធនធានមនុស្ស និងហិរញ្ញវត្ថុឲ្យកាន់តែច្រើនឡើងដើម្បីបញ្ឈប់នូវការរំលោភបំពានសិទ្ធិមនុស្សដ៏ដែលមិនអាចទទួលយកបាននេះ"។

ថ្លែងនៅក្នុងកិច្ចប្រជុំនេះដែរ លោកស្រី Wenny Kusuma តំណាង អង្គការ UN Women ប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា៖ "ថ្ងៃនេះ យើងបានធ្វើដំណើរមកដល់ពាក់កណ្តាលផ្លូវនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨) ដោយមានអារម្មណ៍ចម្រុះ ពីព្រោះនៅមានការងារជាច្រើនទៀតដែលយើងត្រូវធ្វើ។ យោងតាមការសិក្សាស្រាវជ្រាវថ្នាក់ជាតិមួយដែលគាំទ្រដោយអង្គការ UN Women និងអង្គការសុខភាពពិភពលោក ដែលត្រូវបានផ្សព្វផ្សាយនៅចុងឆ្នាំកន្លងទៅនេះ បានឲ្យដឹងថា ស្ត្រីកម្ពុជាម្នាក់ក្នុងចំណោម ៥នាក់ អាយុពី ១៥ ដល់ ៦៤ឆ្នាំ ដែលធ្លាប់

រៀបការ ឬមានដៃគូ បានទទួលរងនូវអំពើហិង្សាលើរាងកាយ និង/ឬអំពើហិង្សាផ្លូវភេទ ដោយដៃគូជិតស្និទ្ធនៅក្នុងមួយជីវិតរបស់ពួកគេ។ មានសិក្សាស្រាវជ្រាវមួយទៀតរបស់អង្គការសហប្រជាជាតិដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៣ បានរកឃើញថា ជនល្មើសជាបុរសកម្ពុជាស្ទើរជិតពាក់កណ្តាលមិនដែលបានប្រឈមនឹងការដោះស្រាយតាមនីតិវិធីច្បាប់ទាល់តែសោះ។ ទិន្នន័យទាំងអស់នេះ វាកំពុង ពញ្ញាក់យើង និងបង្ហាញថា ការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រីពីរដ្ឋាភិបាលកម្ពុជានៅមិនទាន់គ្រប់គ្រាន់នៅឡើយ"។

នៅក្នុងសុន្ទរកថា របស់បណ្ឌិត **Ludgera Klemp** កុងស៊ុលនៃស្ថានទូតអាល្លឺម៉ង់បានមានប្រសាសន៍ថា៖ "ប្រទេសអាល្លឺម៉ង់បានធ្វើការគាំទ្រក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាលចំនួនបួន (រួមមានអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ អង្គការចិត្តសង្គម អន្តរវប្បធម៌ អង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា និងអង្គការបន្ទាយស្រី) ដើម្បីពង្រឹងនូវកិច្ចសម្របសម្រួល គុណភាព និងលទ្ធភាពទទួលបាននូវសេវារបស់ស្ត្រី និងក្មេងស្រីរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ក្នុងឆ្នាំ២០១៤ និង ២០១៥ ស្ត្រី និងក្មេងស្រីលើសពី៤០០០នាក់ ដែលរួចផុតពីអំពើហិង្សាដោយដៃគូជិតស្និទ និងអំពើហិង្សាផ្លូវភេទ ព្រមទាំងកូនៗរបស់ពួកគាត់បានទទួលសេវាជំនួយផ្សេងៗ នៅក្នុងខេត្តកំពង់ធំ និងខេត្តសៀមរាប។ អំពើហិង្សាលើពលករស្ត្រីកម្ពុជា ព្រមទាំងអំពើជួញដូរស្ត្រី និងក្មេងស្រីនៅតែជាបញ្ហាអាទិភាព។

នៅក្នុងកិច្ចប្រជុំថ្ងៃនេះ មានក្រសួងចំនួន ៤ (ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងព័ត៌មាន) ក៏បានពន្យល់អំពីវឌ្ឍនៈភាព និងបញ្ហាប្រឈមទាំងឡាយ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋ ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី មុនពេលអំពើហិង្សានេះកើតឡើង។ លើសពីនេះ តំណាង មន្ទីរកិច្ចការនារី ខេត្តសៀមរាប និងខេត្តកំពង់ធំ និងតំណាងពីអង្គការមិនមែនរដ្ឋាភិបាលទាំង ៤ បានធ្វើបទបង្ហាញអំពីការអនុវត្តល្អៗ និងមេរៀនដែលបានរៀនសូត្រ អំពីការឆ្លើយតបរបស់ពួកគេចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅថ្នាក់ក្រោមជាតិ។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំនៅក្រោមក្របខណ្ឌនៃក្រុមការងារបច្ចេកទេសស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបានបង្កើតនៅក្នុងឆ្នាំ ២០១២ ដោយក្រសួងកិច្ចការនារី និងជួយគាំទ្រដោយអង្គការ GIZ អង្គការ UN Women ដោយមានមូលនិធិពីរដ្ឋាភិបាលអាល្លឺម៉ង់ និងរដ្ឋាភិបាលអូស្ត្រាលី។ ក្រុមការងារនេះមានសមាជិកមកពីក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍។

***

**សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅក្នុងគេហទំព័ររបស់ក្រសួងកិច្ចការនារីតាមអាស័យដ្ឋាន៖**

https://www.facebook.com/mowa.gov.kh

***

**ឬសម្រាប់ព័ត៌មានបន្ថែមទៀត សូមទំនាក់ទំនងមក**

- **លោកផុន ពុធបុរី** នាយកដ្ឋានព័ត៌មាននៃក្រសួងកិច្ចការនារី អ៊ីម៉េល៖ puthborey@gmail.com; ទូរស័ព្ទ: (+855) 129 905 19
- **លោក** Rodrigo Montero Cano, ទីប្រឹក្សាទំនាក់ទំនងនៃគម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី អង្គការជីអាយហ្សិត អ៊ីម៉េល៖ rodrigo.montero@giz.de;

  ទូរស័ព្ទ៖ (+ 855) 12 92 37 71
- **អ្នកស្រី** Mariken Bruusgaard Harbitz មន្ត្រីទំនាក់ទំនង អង្គការUN Women

អ៊ីម៉េល៖ mariken.harbitz@unwomen.org; ទូរស័ព្ទ៖ +855 (0)12 210 325